# របៀបមើលរកគូរព្រេង

+ជាដំបូងត្រូវយកថ្ងៃកំណើតមកតាំងជាលេខ ហើយយកខែកំណើតមកគុណ ហើយយកឆ្នាំកំណើតទៅបូកថែមទៀត ទើបយក៧ទៅសង ។ ឱ្យរាប់ឆ្នាំជូតជាលេខ១ ខែមិគសិរ ជាខែទី១ និងថ្ងៃអាទិត្យជាថ្ងៃទី១ដូចគ្នា ។

+បើឃើញលេខសេសប៉ុន្មាន នឹងមានទំនាយដូចខាងក្រោមនេះ :

បើសេសលេខ១ ទំនាយថាគូរព្រេងវាសនា នៅទិសពាយ័ព្យ ឬ អាគ្នេយ៍ រូបរាងតូចស្តើង សំបុរសំណែ្តកបាយ ជាមនុស្សកំព្រា មានប្រាជ្ញាស្មារតីវាងវៃ សំដីច្រើន តែមានចិត្តដាច់ខាត ។

បើសេសលេខ២ ទំនាយថាគូរព្រេងវាសនា នៅទិសបូពា៌ ឬ បស្ចឹម រូបរាងតូចទ្រនាប់ សំបុរស ស្អាតកិរិយាមារយាទ និងសំដីសំដៅទន់ភ្លន់ មានចិត្តថ្លើមស្មោះត្រង់នឹងស្មារតី ព្រមទាំងញាតិសន្តាន ។

បើសេសលេខ៣ ទំនាយថា គូរព្រេងវាសនាស្ថិតនៅទិសឦសាន និងនិរតី ជាមនុស្សមានធំ សម្បើមសំបុរខ្មៅស្រអែម ជាមនុស្សសំបូរទៅដោយចំណេះវិជ្ជា និងមានវ័យចំណាស់បន្តិច ។

បើសេសលេខ៤ ទំនាយថា គូរព្រេងវាសនាស្ថិតនៅទិសឧត្តរ និងទិសទក្សិណ រូបរាងខ្ពស់ដំបងសំបុរសក្រហម សក់រួញ មុខតូច និស្ស័យចិត្តថ្លើមច្រើនងង៉ក់បន្តិច លុះចេរកាលនឹងបានស្តុកស្តម្ភទៅដោយភោគទ្រព្យ ។

បើសេសលេខ៥ ទំនាយថា គូរព្រេងវាសនាស្ថិតនៅទិសទក្សិណ និងទិសនិរតី មុខជ្រុង សំបុរស វាចាច្រើនមានបញ្ញាវាងវៃ តែមានចំណាស់បន្តិច ។

បើសេសលេខ៦ ទំនាយថា គូរព្រេងវាសនាស្ថិតនៅទិសបស្ចឹម និងទិសនិរតី ជាមនុស្សមានរូប រាងខ្ពស់សំបុរលឿង ជាមនុស្សឧស្សាហ៍ព្យាយាមនឹងការងារ តែមានចិត្តឆេវឆាវបន្តិច ។

បើសេសលេខ៧ ទំនាយថា គូរព្រេងវាសនាស្ថិតនៅអាគ្នេយ៍ ឬ ពាយ័ព្យ មាឌធំដំបង សំបុរខ្មៅសំដីសំដៅខ្មោះខ្នួរ និយាយស្តីមិនទៀង ជាមនុស្សកំណាញ់ទ្រីស្នូរ ។